# ព្រឹត្តិបត្រពាណិជ្ជកម្ម
# iTRADE BULLETIN

## INSIDE

**Infographic**
**“Cambodia-China Free Trade Agreement (CCFTA)”**

**Local & Global News**

**Opinion Article**
**“How will WTO find room for solutions to Russia-Ukraine War?”**

វ៉ុល០១ | លេខ០៥ | ខែឧសភា ឆ្នាំ២០២២
VOLUME 01 | ISSUE 05 | MAY 2022



# កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន
# CAMBODIA-CHINA FREE TRADE AGREEMENT (CCFTA)

កិច្ចព្រមព្រៀង CCFTA ឈរលើបទប្បញ្ញត្តិរបស់អង្គការ WTO (មាត្រា XXIV of GATT ១៩៩៤ និងមាត្រា V of GATS ១៩៩៥) និងផ្អែកលើគោលការណ៍បដិការ (Reciprocity)





កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី **ទី១** ដែលព្រះរាជាណាចក្រកម្ពុជាសម្រេចបាន

## កាលបរិច្ឆេទសំខាន់ៗ

- **២២ មករា ២០១៩** — ជំនួបថ្នាក់ដឹកនាំ នៃប្រទេសទាំងពីរ ពិនិត្យលទ្ធភាពបង្កើតកិច្ចព្រមព្រៀង នៅទីក្រុងប៉េកាំង
- **២០ មករា ២០២០** — ចាប់ផ្តើមចរចាជុំទី១ នៅទីក្រុងប៉េកាំង
- **០៩ មេសា ២០២០** — ចរចាជុំទី២ តាមរយៈប្រព័ន្ធវីដេអូ
- **២០ មិថុនា ២០២០** — ចរចាជុំទី៣ តាមរយៈប្រព័ន្ធវីដេអូ
- **២០ កក្កដា ២០២០** — បញ្ចប់ការចរចា
- **១២ តុលា ២០២០** — ចុះហត្ថលេខា នៅរាជធានីភ្នំពេញ
- **០១ មករា ២០២២** — កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិនចូលជាធរមាន

## ពាណិជ្ជកម្មទ្វេភាគី

២០១៧ | ៦,០៣ ប៊ីលានដុល្លារ

២០២១ | ១១,១៩ ប៊ីលានដុល្លារ

កំណើនជាមធ្យមប្រចាំឆ្នាំ ១៧.១៩%



## មុខទំនិញសំខាន់ៗដែលកម្ពុជាទទួលបានភាពអនុគ្រោះពន្ធ ពីកិច្ចព្រមព្រៀងនេះ

**ទំនិញកសិកម្ម** — សត្វរស់ សាច់សត្វ ត្រី និងពពួកសត្វរស់នៅក្នុងទឹក ផលិតផលទឹកដោះ សត្វស្លាប ទឹកឃ្មុំ បន្លែ ផ្លែឈើ គ្រាប់ធញ្ញជាតិផ្សេងៗ គ្រាប់ និងផ្លែធញ្ញជាតិ។ល។

**កសិកម្មកែច្នៃ** — ដំណាំឧស្សាហកម្មនានា ជ័រ និងជ័រចម្រាញ់ពីរុក្ខជាតិផ្សេងៗ ខ្លាញ់សត្វ និងប្រេងរុក្ខជាតិនានា គ្រឿងបរិភោគដែលកែច្នៃរួច ភេសជ្ជៈ វត្ថុដែលមានជាតិស្រវឹង ទឹកខ្មេះ (លើកលែងស្ករស និងថ្នាំជក់)។ល។

**ឧស្សាហកម្ម** — ផលិតផលរ៉ែ ក្រោមផលិតផលនៃឧស្សាហកម្មគីមី ឬ ឧស្សាហកម្មជាសម្ព័ន្ធ ដូចជា ឱសថ សារធាតុផ្សេងៗ និងប្លាស្ទិក ផលិតផលធ្វើពីប្លាស្ទិកជាដើម។ល។

## ទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ចិន




**១,៥១ ប៊ីលានដុល្លារ**
ទំហំការនាំចេញរបស់កម្ពុជាទៅប្រទេសចិនក្នុងឆ្នាំ២០២១

**+៧.៨២%**
កំណើនការនាំចេញរបស់កម្ពុជាទៅប្រទេសចិនក្នុងឆ្នាំ២០២១

**+៣១%**
កំណើនពាណិជ្ជកម្មទ្វេភាគី ក្នុងរយៈពេល ៤ខែដំបូង ឆ្នាំ២០២២

**ចិន គឺជាភាគីនាំចេញធំជាងគេទី ៣ ឬស្មើ ៨% នៃការនាំចេញសរុប របស់កម្ពុជាក្នុងឆ្នាំ២០២១**

**ប្រមាណ ៩៨%**
ការលើកលែងពន្ធ នៃការនាំចេញទៅប្រទេសចិន ដែល **កម្ពុជា** ទទួលបាន



**ប្រមាណ ៩០%**
ការលើកលែងពន្ធ នៃការនាំចូលមកប្រទេសកម្ពុជា ដែល **ចិន** ទទួលបាន



(គិតត្រឹមថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២)

**២៨,៧២៤,៨០០ ដូស**
វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ ជាជំនួយរបស់ចិន

សម្រាប់ការទាញយកឯកសារពាក់ព័ន្ធកិច្ចព្រមព្រៀង CCFTA និងឯកសារព័ត៌មានពាណិជ្ជកម្ម

រៀបចំដោយ

ប្រភព៖ ក្រសួងពាណិជ្ជកម្មកម្ពុជា, ក្រសួងពាណិជ្ជកម្មចិន, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

# កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន

# CAMBODIA-CHINA FREE TRADE AGREEMENT (CCFTA)



**CCFTA conforms with WTO rules**
(Article XXIV of GATT 1994 and Article V of GATS 1995 and bases on the principal of reciprocity).



**1st** Bilateral Free Trade Agreements CAMBODIA has achieved

## MILESTONES

- **22 January 2019** – Meeting of the both leaders to explore possibilities in establishing FTA in Beijing
- **20 January 2020** – 1st round of negotiation in Beijing
- **09 April 2020** – 2nd round of negotiations via remote video
- **20 June 2020** – 3rd round of negotiations via remote video
- **20 July 2020** – Conclusion of CCFTA negotiations
- **12 October 2020** – Signing Ceremony of CCFTA
- **01 January 2022** – CCFTA took effect

## BILATERAL TRADE

2017 | $6.03 billion

2021 | $11.19 billion

Annual average growth 17.69%



## Cambodia's Major Products Subject to Preferential Tariffs under CCFTA

**Agricultural Products**: Live animals, meats, fishes and other aquatic animals, dairy products, birds, natural honey, vegetables, fruits, nuts, and cereals

**Processing Agricultural Products**: Industrial plants, gums, resins, animal and vegetable fats and oils, prepared foodstuffs, beverages, spirits, vinegar (other than tobacco and white sugars)

**Industrial Products**: Mineral products, products of chemical or allied industries such as pharmaceutical products, other substances, and plastics and articles thereof.

## BILATERAL TRADE VOLUME




**$1.51 BILLION**
Total volume of Cambodia's export to China in 2021

**+7.82%**
Increase in Cambodia's export to China in 2021

**+31%**
Increase in bilateral trade in the first 4 months of 2022

3rd
**CHINA** is the **Third Largest Export Market** amassing **8%** of **Cambodia's total export in 2021**

**Approx. 98%** Tariff-Free on the Cambodia's export to China



**Approx. 90%** Tariff-free on the China's export to Cambodia



(As of 29 March 2022)
**28,724,800 doses**
Covid-19 vaccines donated from China

Please scan to download related documents of CCFTA and iTrade Bulletin

Organized by

Source: Ministry of Commerce of Cambodia, Ministry of Commerce of China, General Department of Customs and Excise of Cambodia

## កម្ពុជា មានបំណងពង្រឹងពាណិជ្ជកម្មនិង កិច្ចសហប្រតិបត្តិការបន្ថែមទៀតជាមួយ ក្រុមហ៊ុនអាមេរិក

ប្រភព៖ The Star

សភាពាណិជ្ជកម្មកម្ពុជា ជំរុញឱ្យវិនិយោគិនអាម៉េរិក មកសហការជាមួយវិនិយោគិនកម្ពុជា ក្នុងវិស័យសំណង់ អចលនទ្រព្យ កសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម។ ជំនួបពាណិជ្ជកម្មនេះ ត្រូវបានធ្វើឡើងក្នុងដំណើរទស្សនកិច្ចរបស់សម្ដេចនាយករដ្ឋមន្រ្តី **ហ៊ុន សែន** នៅអាម៉េរិកក្នុងកិច្ចប្រជុំកំពូលពិសេសអាស៊ាន-អាម៉េរិក កាលពីថ្ងៃទី១២ ខែឧសភា កន្លងទៅ។ ជំនួបពាណិជ្ជកម្មនេះ ក៏បានពិភាក្សាអំពីការលើកទឹកចិត្តផ្នែកវិនិយោគ និងវិស័យសក្ដានុពលពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា។ ឧកញ៉ា លី យុនថៃ ប្រធានសមាគមស្បែកជើងកម្ពុជា បានឱ្យដឹងថា ក្នុងត្រីមាសទី១នៃឆ្នាំ ២០២២ ទំហំទឹកប្រាក់នាំចេញស្បែកជើងកម្ពុជាទៅកាន់អាម៉េរិកបានកើនដល់ ១៥២ លានដុល្លារអាម៉េរិក ឬ កើន ៤៤% ធៀបនឹងឆ្នាំមុន។ គួររំលឹកផងដែរថា ទំហំពាណិជ្ជកម្មសរុបរវាងកម្ពុជា និងអាម៉េរិកបានកើនឡើង ៣២,៦% ពី ៦,៩ ប៊ីលានដុល្លារ ក្នុងឆ្នាំ២០២០ ទៅ ៩,២ ប៊ីលានដុល្លារ ក្នុងឆ្នាំ២០២១។ យោងតាមការិយាល័យជំរឿនអាម៉េរិក ក្នុងឆ្នាំ២០២១ ការនាំចេញរបស់កម្ពុជាទៅកាន់អាម៉េរិកមានតម្លៃប្រមាណ ៨,៧ ប៊ីលានដុល្លារ ខណៈដែលការនាំចូលមានតម្លៃប្រមាណ ៤១៣,៧ លានដុល្លារ។ ចុចទីនេះដើម្បីអានបន្ថែម

## ការនាំចេញរបស់កម្ពុជាកើនឡើង ៣២% ក្នុងរយៈពេល ៤ ខែដំបូង

ប្រភព៖ Khmer Times

ប្រទេសកម្ពុជា បាននាំចេញទំនិញក្នុងតម្លៃសរុបប្រមាណ ៧,៦១ ប៊ីលានដុល្លារអាម៉េរិកក្នុងរយៈពេល ៤ខែដំបូងក្នុងឆ្នាំ២០២២ គឺកើនឡើង ៣២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ (អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា)។ អាម៉េរិក គឺជាទីផ្សារដ៏ធំមួយសម្រាប់ការនាំចេញរបស់កម្ពុជាក្នុងទឹកប្រាក់ប្រមាណ ២,៩២ ប៊ីលានដុល្លារអាម៉េរិក បន្ទាប់មកគឺវៀតណាម (៩៧៧ លានដុល្លារអាម៉េរិក) និង ចិន (៤២៣ លានដុល្លារអាម៉េរិក) ក្នុងរយៈពេលបួនខែដំបូងនៃឆ្នាំ ២០២២។ ដោយឡែក ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងដៃគូពាណិជ្ជកម្មដទៃទៀតមានទឹកប្រាក់សរុបប្រមាណ ១៧,៦៥ ប៊ីលានដុល្លារអាម៉េរិកក្នុងរយៈពេលដដែល គឺកើនឡើងប្រមាណ ១៥,៥% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ចុចទីនេះដើម្បីអានបន្ថែម

## ថវិកាជិត ១,៣ ប៊ីលានដុល្លារអាម៉េរិក ជួយគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

ប្រភព៖ ភ្នំពេញប៉ុស្តិ៍

ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា បានបង្ហាញថា ទឹកប្រាក់ ១,២៩ ប៊ីលានដុល្លារអាម៉េរិក ត្រូវបានផ្តល់ជូនកម្ពុជាតាមរយៈដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ពីឆ្នាំ២០១៥ ដល់ ២០២០ ដែលអាចជួយកម្ពុជាក្នុងការធ្វើពិពិធកម្មឧស្សាហកម្មកម្មន្តសាល។ វិធានការសំខាន់ៗចំនួនបួនគាំទ្រដោយដៃគូអភិវឌ្ឍន៍រួមមាន ការកាត់បន្ថយថ្លៃអគ្គិសនី ការរៀបចំផែនការមេសម្រាប់

ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន ការពង្រឹងទីផ្សារការងារ និងការរៀបចំផែនការមេលម្អិតដើម្បីប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ក្រោមការគាំទ្រជាទឹកប្រាក់ប្រមាណ៩៣៨,៥លានដុល្លារ។ ការវិភាគពីលទ្ធផលនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មបានបង្ហាញថា ការរួមចំណែករបស់វិស័យឧស្សាហកម្មក្នុងផលិតផលក្នុងស្រុកសរុប កើនឡើងពី ២៧,៧% ក្នុងឆ្នាំ២០១៥ ដល់ ៣៤,២% ក្នុងឆ្នាំ២០១៩ ដែលមានអត្រា ៣០% ខ្ពស់ជាងគោលដៅដែលបានដាក់សម្រាប់ឆ្នាំ២០២៥។ ផ្ទុយមកវិញ ការរួមចំណែករបស់វិស័យកម្មន្តសាលក្នុងផលិតផលក្នុងស្រុកសរុប មានការកើនឡើងយឺតជាងការរំពឹងទុក ពី ១៦% ក្នុងឆ្នាំ២០១៥ ទៅ ១៦,៣% ក្នុងឆ្នាំ២០១៩ ទាបជាងកំណើនគោលដៅ ២០% ក្នុងឆ្នាំ២០២២។ [ចុចទីនេះដើម្បីអានបន្ថែម]

## ក្រុមហ៊ុនចិនបោះទុនវិនិយោគ ៧០លានដុល្លារអាមេរិក លើដំណាំស្វាយ

ប្រភព៖ ភ្នំពេញប៉ុស្តិ៍

ក្រុមហ៊ុន Green Sea Agriculture កំពុងដាំដុះស្វាយចំនួនប្រាំមួយប្រភេទដែលនាំចូលពីតៃវ៉ាន់ អាមេរិក និងអូស្ត្រាលី នៅក្នុងខេត្តស្ទឹងត្រែង ជាមួយផ្ទៃដីដាំដុះចំនួន ១.២០០ ហិកតា ស្មើនឹង ១២% នៃផែនការមេ។ បច្ចុប្បន្ន ក្រុមហ៊ុនបានវិនិយោគទឹកប្រាក់ចំនួន ៧០ លានដុល្លារអាមេរិក ទៅលើការដាំដុះ និងគ្រោងវិនិយោគ ៥០០ លានដុល្លារបន្ថែមទៀត ដើម្បីពង្រីកការដាំដុះ និងនាំចេញទៅកាន់ទីផ្សារចិនក្នុងទ្រង់ទ្រាយធំ។ តាមគម្រោង ស្វាយនេះនឹងត្រូវដឹកជញ្ជូនទៅកាន់ទីផ្សារចិនតាមរយៈកំពង់ផែវៀតណាម ថៃ និងខេត្តព្រះសីហនុ។ ប៉ុន្តែបច្ចុប្បន្ននេះ បន្ទាប់ពីប្រមូលផលហើយ ក្រុមហ៊ុនកំពុងប្រឈមបញ្ហាបន្តិចបន្តួចក្នុងការដឹកជញ្ជូន។ យោងរបាយការណ៍របស់អគ្គនាយកដ្ឋានកសិកម្ម ក្នុងឆមាសទីមួយ នៃឆ្នាំ២០២២ ការនាំចេញស្វាយស្រស់មានចំនួន ៨១.៤១៨ តោន ថយចុះ ២០% និងការនាំចេញស្វាយស្ងួតមានចំនួន ៥.១៣៦ តោន ថយចុះ ១៣,៤៣%។ [ចុចទីនេះដើម្បីអានបន្ថែម]

**Cambodia Seeks More Trade, Cooperation with US Firms**

Source: The Star

Cambodia Chamber of Commerce has urged US investors to look into collaborations with Cambodians in construction and real estate, agriculture, services and trade. The meeting, held in conjunction with Prime Minister Hun Sen's visit to the US for a high-level Asean-US Special Summit on May 12, also discussed investment incentives and potential in key business sectors in Cambodia. According to Cambodia Footwear Association's President Ly Kunthai, footwear exports to the US grew more than 44 per cent year-on-year to $152 million in the first quarter of 2022. To recap, total trade between Cambodia and the US rose by 32.6 per cent to US$9.2 billion in 2021 from $6.9 billion in 2020. Of the figure in 2021, exports to the US amounted to $8.7 billion while imports from the US stood at $413.7 million, data from the US Census Bureau showed. Click here to read more

**Cambodia's Exports Jump 32 Percent in First Four Months**

Source: Khmer Times

Cambodia exported goods for a total of $7,606 million in the first four months this year, a 32 percent increase over the same period last year, data from the General Department of Customs and Excises showed. From the January to April period, the US was the biggest market for Cambodia's exports with a total value of $2,923 million, followed by Vietnam and China of $977 million and $423 million, respectively. The data stated the bilateral trade between Cambodia and its trade partners amounted to $17,649 million during the January-April period, a 15.5 percent increase compared to the same period of last year. Click here to read more

**Nearly $1.3B Spent to Aid Industry Development Policy**

Source: Phnom Penh Post

The latest figures from the Cambodia Cooperative Financing Database showed that development partners provided $1.287 billion in financing to support the implementation of Cambodia Industrial Development Policy (IDP) between 2015 and 2020, which aims to help the Kingdom diversify its manufacturing industries. Four primary measures supported by development partners include lowering electricity prices, the preparation of the master plan for the development of transport and logistics systems, strengthening the labour market, and detailing the master plan to transform Preah Sihanouk province into a Model Multi-Purpose Special Economic Zone, the latter of which received the most support at $938.5 million. Analysis of the outcomes of the IDP policy shows that the industrial sector's share of the gross domestic product (GDP) increased from 27.7 per cent in 2015 to 34.2 per cent in 2019, which is 30 per cent higher than the target set for 2025. The manufacturing sector's share of the GDP, on the other hand, grew slower than expected, rising from 16 per cent in 2015 to 16.3 per cent in 2019, with a target of 20 per cent for 2022. Click here to read more

**China Firm Invests $70M in Mango Project**

Source: Phnom Penh Post

Green Sea Agriculture company has been growing six varieties of mangoes, imported from Taiwan, the US and Australia, in Stung Treng province. Its plantation currently covers a total area of 1,200ha, equivalent to 12 per cent of its master plan. To date, it has invested nearly $70 million in its mango plantation, and revealed plans to invest an additional $500 million to expand mango cultivation and export the fruit to the Chinese market on a large scale. The company said its objective was to export to China via Vietnam, Thailand and the Preah Sihanouk ports. The company acknowledged it has been facing teething problems with transportation since its initial harvest. According to a General Directorate of Agriculture's report, in the first quarter of 2022, the export of fresh mangoes totalled 81,418 tonnes, a decrease of 20.73 per cent, and exports of dried mango amounted to 5,136 tonnes, falling by 13.43 per cent. Click here to read more

## ចិន រិះគន់ក្របខ័ណ្ឌសេដ្ឋកិច្ចដែលស្នើឡើងដោយអាមេរិក ខណៈលោកបៃដិនទទួលស្វាគមន៍ថ្នាក់ដឹកនាំអាស៊ីអាគ្នេយ៍

ប្រភព៖ Eurasia Review

រដ្ឋធានីប៉េកាំង បានរិះគន់លើក្របខ័ណ្ឌសេដ្ឋកិច្ចឥណ្ឌូប៉ាស៊ីហ្វិកដែលស្នើឡើងដោយសហរដ្ឋអាមេរិក ដោយចោទថា ក្របខ័ណ្ឌនេះ ជាការព្យាយាមរបស់អាមេរិកក្នុងការទាក់ទាញប្រទេសអាស៊ីអាគ្នេយ៍ "ដើម្បីផ្តាច់ទំនាក់ទំនងជាមួយចិន"។ ក្របខ័ណ្ឌនេះ មានគោលដៅជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ដោយដាក់ចេញនូវវិធានពាណិជ្ជកម្ម កិច្ចសម្រួលពាណិជ្ជកម្ម ស្តង់ដារសម្រាប់សេដ្ឋកិច្ចឌីជីថលនិងបច្ចេកវិទ្យា ភាពរឹងមាំនៃខ្សែច្រវាក់ផ្គត់ផ្គង់ ការកាត់បន្ថយឧស្ម័នកាបូននិងជំរុញការប្រើប្រាស់ថាមពលស្អាត ហេដ្ឋារចនាសម្ព័ន្ធ ស្តង់ដារការងារ និងផលប្រយោជន៍ផ្សេងទៀត ដោយគ្មានចិន។ អាស្រ័យហេតុនេះ ចិនបានព្រមានអាមេរិកថា "អាស៊ីប៉ាស៊ីហ្វិកមិនមែនជាក្តារអុកសម្រាប់ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយនោះទេ" ហើយក្របខ័ណ្ឌសហប្រតិបត្តិការតំបន់ណាមួយគួរតែធ្វើឡើងឱ្យស្របតាម "គោលការណ៍នៃការគោរពអធិបតេយ្យភាព និងមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងប្រទេសដទៃ"។ ចិនជឿថា ក្របខ័ណ្ឌសេដ្ឋកិច្ចឥណ្ឌូប៉ាស៊ីហ្វិក ត្រូវបានតាក់តែងឡើងដើម្បីដោះស្រាយបញ្ហាទំនាក់ទំនងអតីតកាលរបស់អាមេរិកជាមួយតំបន់អាស៊ីអាគ្នេយ៍ដែលផ្តោតតែលើបញ្ហាសន្តិសុខ ដោយមិនបានគិតគូពីបញ្ហាសេដ្ឋកិច្ច"។ ក្នុងចំណោមសមាជិកអាស៊ានទាំង១០ មានតែសិង្ហបុរីនិងហ្វីលីពីនប៉ុណ្ណោះដែលត្រូវបានគេរំពឹងថា នឹងក្លាយជាស្ថាបនិកក្នុងការចរចាក្របខ័ណ្ឌសេដ្ឋកិច្ចឥណ្ឌូប៉ាស៊ីហ្វិកនេះ។ ចុចទីនេះដើម្បីអានបន្ថែម

## ឥណ្ឌាចង់ឱ្យ WTO ដើរតួនាទីរបស់ខ្លួនក្នុងការទប់ស្កាត់អតិផរណាពិភពលោក

ប្រភព៖ The Times of India

ឥណ្ឌា ចង់ឱ្យអង្គការពាណិជ្ជកម្មពិភពលោក (WTO) ដើរតួនាទីរបស់ខ្លួនក្នុងការទប់ស្កាត់អតិផរណាពិភពលោកដែលកំពុងប៉ះពាល់ដល់សេដ្ឋកិច្ចនៃសមាជិកភាគច្រើន។ យោងតាមសេចក្តីថ្លែងការណ៍មួយរបស់ឥណ្ឌា ដែលផ្តល់ដោយអគ្គរដ្ឋទូតតំណាងអចិន្ត្រៃយ៍ប្រចាំ WTO អាទិភាពកំពូលរបស់ WTO គួរតែជាការស្តារសេដ្ឋកិច្ចឡើងវិញ និងទ្រទ្រង់កំណើនក្រោយជម្ងឺកូវីដ-១៩ និងក្នុងអំឡុងពេលស្ថានភាពជម្លោះបច្ចុប្បន្ន។ "ស្ថានភាពបច្ចុប្បន្នមានបញ្ហាសំខាន់ថ្មីមួយ...ហើយបញ្ហានោះគឺការកើនឡើងអតិផរណាភាគច្រើន ក្នុងសេដ្ឋកិច្ចក្នុងស្រុក"។ លោកបាននិយាយថា "ទាំងនេះត្រូវបានមើលឃើញតាមរយៈវិបត្តិស្បៀងអាហារ ជី និងប្រេងឥន្ធនៈ ហើយវានឹងបំផ្លិចបំផ្លាញសេដ្ឋកិច្ច និងលុបបំបាត់ផលចំណេញជាច្រើន ដែលបានទទួលមុនជំងឺរាតត្បាត..."។ ចុចទីនេះដើម្បីអានបន្ថែម

## លោក បៃដិន មិនបង្ហាញគោលជំហរលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម ដែលជាហានិភ័យនៃភាពឯកោនៅអាស៊ី

ប្រភព៖ Bloomberg

បណ្តាប្រទេសអាស៊ីអាគ្នេយ៍ មានការខកចិត្តកាន់តែខ្លាំងចំពោះអាមេរិក ជាមួយនឹងកង្វះវត្តមានភាពលើបញ្ហាពាណិជ្ជកម្ម ដែលធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងរបស់លោក ចូ បៃដិន ក្នុងការពង្រឹងទំនាក់ទំនងជាមួយមេដឹកនាំក្នុងតំបន់ នៅក្នុងកិច្ចប្រជុំកំពូលថ្ងៃ១២-១៣ ខែឧសភា ឆ្នាំ២០២២ នៅទីក្រុងវ៉ាស៊ីនតោន។

រដ្ឋបាលអាម៉េរិកបានគូសបញ្ជាក់ជាថ្មី អំពីសារសំខាន់នៃភាពជាអ្នកដឹកនាំរបស់អាម៉េរិកនៅក្នុងតំបន់អាស៊ី និងការកសាងទំនាក់ទំនង ដើម្បីទប់ទល់នឹងឥទ្ធិពលចិន។ ប៉ុន្តែ នៅពេលគេនិយាយអំពីខ្លឹមសារជាពិសេសកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាម៉េរិកបានបង្ហាញគោលជំហរតិចតួចចំពោះបញ្ហានេះ។ គំនិតផ្តួចផ្តើមដ៏សំខាន់របស់អាម៉េរិកនៅពេលនេះ(ក្របខ័ណ្ឌសេដ្ឋកិច្ចឥណ្ឌូប៉ាស៊ីហ្វិក) ត្រូវបានគេសន្មត់ថា ដើម្បីដោះស្រាយបញ្ហាខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់ ហេដ្ឋារចនាសម្ព័ន្ធ និងបញ្ហាផ្សេងទៀត។ ប៉ុន្តែព័ត៌មានលម្អិតគឺមានភាពស្រពេចស្រពិល ហើយរដ្ឋបាលអាម៉េរិកបានសង្កត់ធ្ងន់ថា ក្របខ័ណ្ឌនេះនឹងមិនរួមបញ្ចូលការបន្ថយពន្ធ ឬក៏ការបើកច្រកទីផ្សារអាម៉េរិកប្រសើរជាងមុនទេ។ ផ្ទុយទៅវិញ អាទិភាពចម្បងរបស់អាម៉េរិកនៅអាស៊ី គឺការពង្រឹងទំនាក់ទំនងការពារជាតិ ដែលជាផ្នែកនៃកិច្ចខិតខំប្រឹងប្រែងដ៏ទូលំទូលាយ ដើម្បីទប់ទល់នឹងឥទ្ធិពលចិន។ ចុចទីនេះដើម្បីអានបន្ថែម

## អៀរឡង់ខាងជើង៖ តើសហភាពអឺរ៉ុប និងអង់គ្លេសអាចប្រឈមនឹងសង្គ្រាមពាណិជ្ជកម្មទេ?

ប្រភព៖ BBC

មន្ត្រីសហភាពអឺរ៉ុប បានព្រមានជាថ្មីម្តងទៀតអំពី ផលវិបាក "ធ្ងន់ធ្ងរ" ប្រសិនបើចក្រភពអង់គ្លេសបដិសេធជំពូកខ្លះនៃពិធីសារអៀរឡង់ខាងជើង។ កាលពីខែវិច្ឆិកា ឆ្នាំ២០២១ កន្លងទៅ លោក សៃម៉ុន ខូវនេយ រដ្ឋមន្ត្រីការបរទេសអៀរឡង់ខាងជើង បានព្រមានថា កិច្ចព្រមព្រៀងពាណិជ្ជកម្មនិងកិច្ចសហប្រតិបត្តិការ ដែលជានាពាណិជ្ជកម្មពន្ធសេរីនិងកូតាសេរីរវាងសហភាពអឺរ៉ុប និងចក្រភពអង់គ្លេស គឺអាស្រ័យលើការអនុវត្តរបស់ចក្រភពអង់គ្លេសតាមពិធីសារនោះ។ សហភាពអឺរ៉ុបបាននឹងកំពុងស៊ើបអង្កេត លើវិធានការបណ្តោះអាសន្នបន្ទាប់ពីអង់គ្លេស បានចាត់វិធានការពន្យារនីតិវិធីឆ្លងកាត់ព្រំដែនកាលពីឆ្នាំមុន ដែលបានរំលោភលើពិធីសារ។ ក្រោយមក ការស៊ើបអង្កេតនោះត្រូវបានផ្អាកក្រោយកិច្ចចរចា ប៉ុន្តែការស៊ើបអង្កេតនេះអាចនឹងធ្វើបន្តទៀត។ ចុចទីនេះដើម្បីអានបន្ថែម

## បទប្បញ្ញត្តិ "ល្អ" នឹងលើកកម្ពស់ពាណិជ្ជកម្មស្បៀងអាហារប្រកបដោយសុវត្ថិភាព

ប្រភព៖ WTO

នៅក្នុងសិក្ខាសាលាមួយកាលពីថ្ងៃទី១០ ខែឧសភា ដែលរៀបចំដោយធនាគារអភិវឌ្ឍន៍អាស៊ី និង កម្មវិធីសម្របសម្រួលការអភិវឌ្ឍពាណិជ្ជកម្ម (STDF) អ្នកជំនាញផ្នែកអនាម័យនិងភូតគាមអនាម័យ (SPS) បានចែករំលែកការអនុវត្តបទប្បញ្ញត្តិល្អ (GRPs) នៅក្នុងប្រទេសប៊ូតង់ ហ្វីលីពីន និងស្រីលង្កា ដើម្បីពង្រឹងវិធានការ SPS និងសម្រួលពាណិជ្ជកម្មប្រកបដោយសុវត្ថិភាព។ ការពិភាក្សាគឺស្របតាមការណែនាំអនុវត្តក្នុង GRPs ដោយ STDF ដែលបង្ហាញពីវិធីក្នុងការរចនា បង្កើត និងពិនិត្យវិធានការ SPS ដើម្បីសម្រេចបាននូវគោលដៅបង្កើតគោលនយោបាយជាមួយនឹងធនធានមានកំណត់។ GRPs នឹងជួយកែលម្អគុណភាព និងប្រសិទ្ធភាពនៃវិធានការ SPS។ អ្នកចូលរួមបានកត់សម្គាល់ពីអត្ថប្រយោជន៍នៃការប្រើប្រាស់ GRPs រួមទាំងការពង្រឹងអនុលោមភាពតាមកិច្ចព្រមព្រៀង SPS របស់អ្នកនាំចេញ និងស្របតាមស្តង់ដារអន្តរជាតិ ដូចជា Codex Alimentarius អនុសញ្ញាការពាររុក្ខជាតិអន្តរជាតិ និងអង្គការសុខភាពសត្វពិភពលោក ជាមួយការកាត់បន្ថយនីតិវិធីគតិយុត្ត និងបង្កើនការជឿទុកចិត្តលើដំណើរការ បទប្បញ្ញត្តិ SPS។ ចុចទីនេះដើម្បីអានបន្ថែម

## ឥណ្ឌា បើកការនាំចេញស្រូវសាលីទៅប្រទេសដែលខ្វះខាតក្រោយការផ្អាកមួយរយៈខ្លី

ប្រភព៖ Independent

ឥណ្ឌានឹងបើកការនាំចេញស្រូវសាលីដល់ប្រទេសដែលខ្វះខាតស្បៀងអាហារ បន្ទាប់ពីផ្អាកការនាំចេញកាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ស្របពេលដែលមានការព្រួយបារម្ភពីសន្តិសុខស្បៀងរបស់ខ្លួន។ រដ្ឋាភិបាលឥណ្ឌានឹងអនុញ្ញាតឱ្យក្រុមហ៊ុនឯកជនដែលបំពេញតាមការសន្យាពីមុនក្នុងការនាំចេញជិត ៤,៣លានតោនរហូតដល់ខែកក្កដា ឆ្នាំ២០២២។ គួររំឭកផងដែរ រលកកម្ដៅខ្ពស់នារដូវក្ដៅបានបំផ្លាញដំណាំនៅប្រទេសឥណ្ឌា ហើយបានកាត់បន្ថយទិន្នផលដំណាំប្រមាណ១/៤។ ការធ្លាក់ចុះផលិតកម្ម កំណើនការនាំចេញ និងថ្លៃប្រេងឥន្ធនៈខ្ពស់ បាននាំឱ្យមានការឡើងថ្លៃស្រូវសាលីក្នុងស្រុកយ៉ាងខ្លាំងនាពេលថ្មីៗនេះ ដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាជនទូទាំងប្រទេសដោយសារស្រូវសាលីជាអាហារប្រចាំថ្ងៃចាំបាច់បំផុតរបស់ឥណ្ឌា។ ចុចទីនេះដើម្បីអានបន្ថែម

### China Slams Planned US Economic Framework as Biden Hosts Southeast Asian Leaders

Source: Eurasia Review

Beijing has slammed the U.S.-proposed Indo-Pacific Economic Framework (IPEF), calling it an attempt by Washington to lure Southeast Asian countries to "decouple from China". The IPEF seeks to foster economic cooperation in the Indo-Pacific by setting trade rules, trade facilitation, standards for the digital economy and technology, supply chain resiliency, decarbonization and clean energy, infrastructure, worker standards, and other areas of shared interests, without China. Hence, China warned US that the Asia-Pacific is "not a chessboard for geopolitical contest" and any regional cooperation framework should "follow the principle of respecting others' sovereignty and non-interference in others' internal affairs". China believes that the IPEF is designed to "make up for the shortcomings of U.S.'s previous engagement with Southeast Asia, which focused only on security and ignored the economy". Among 10 ASEAN Members, only Singapore and the Philippines are expected to be among the initial group of countries to sign up for the negotiations under IPEF. Click here to read more

### India Wants WTO to Play Its Role in Containing Global Inflation

Source: The Times of India

India wants the World Trade Organisation (WTO) to play its role in containing global inflation, which is impacting most of the economies of the members. According to a statement by Indian Ambassador Permanent Representative to the WTO, the topmost priority for the global trade body should be the revival of the economy and sustain the growth post-pandemic and during the conflict situation. "The present situation has got a new important problem...and that problem is the increasing inflation in most of the domestic economies". "These are getting transmitted through food, fertilizer, and fuel crisis and it is going to devastate the economy. It is going to wipe out a lot of gains which were made before pandemic...," he has said. Click here to read more

### Biden's No-Show on Trade Deals Risks Isolating Friends in Asia

Source: Bloomberg

Southeast Asian nations are increasingly disappointed with the US over a lack of progress on trade issues, undermining President Joe Biden's efforts to strengthen ties with the region's leaders at a Summit this week in Washington. The administration has repeatedly highlighted the importance of US leadership in Asia and building relationships to counter China. But when it comes to substance, specifically free-trade deals, the US has little to show. The main US initiative now, known as the Indo-Pacific Economic Framework, is supposed to deal with regional supply chains, infrastructure and other areas. But details are hazy, and the administration has stressed it won't include lower tariffs or better access to US markets. Instead, the main US priority in Asia has been bolstering defense ties as part of a broader effort to counter China. Click here to read more

### Northern Ireland: Could the EU and UK Face a Trade War?

Source: BBC

European Union officials have repeatedly warned of "serious" consequences if the UK were to override part of the Northern Ireland Protocol. Last November, Ireland's minister for foreign affairs, Simon Coveney, warned that the entire Trade and Co-operation Agreement (TCA) - which exists to ensure tariff-free and quota-free trade between the EU and UK - depends on the UK observing the Protocol. Brussels has been investigating interim measures, after claiming that British action to delay border formalities last year breached the Protocol. It later paused that process after agreeing to negotiations - but it could decide to resume. Click here to read more

## "Smart" Regulations Are to Promote Safe Food Trade

Source: WTO

Sanitary and Phytosanitary (SPS) experts shared how they use Good Regulatory Practices (GRPs) in Bhutan, the Philippines, and Sri Lanka to strengthen SPS measures and facilitate safe trade, at a webinar on 10 May hosted by the Asian Development Bank and the Standards and Trade Development Facility (STDF). Discussions were in line with recommendations in a practical GRP Guide by the STDF, which outlines ways to design, develop and review SPS measures to achieve policymaking goals, with limited resources. GRPs help to improve the quality and effectiveness of SPS measures. Participants noted the benefits of using GRPs, including exporters' improved compliance with the WTO SPS Agreement and greater alignment with international standards — that is, those of the Codex Alimentarius, the International Plant Protection Convention and the World Organisation for Animal Health — as well as a reduced regulatory burden, and increased trust in SPS regulatory processes. Click here to read more

## India Opens to Exporting Wheat to Needy Nations Despite Ban

Source: Independent

India says it will keep a window open to export wheat to food-deficit countries at the government level despite an export ban announced on May 13, 2022, amid its own food security concerns. The government will allow private companies to meet previous commitments to export nearly 4.3 million tons of wheat until July 2022. To be reminded, a record-breaking heat wave this spring damaged crops in India and reduced wheat output by as much as a quarter. Falling production, burgeoning exports and high fuel prices have led to a sharp rise in domestic wheat prices recently, pinching consumers across the country since wheat is one of the most popular food staples in the country. Click here to read more

## តើអង្គការពាណិជ្ជកម្មពិភពលោក អាចចូលរួមបែបណាក្នុងដំណោះស្រាយលើសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន?

**លោក ហោង អៀងឆាយ**
ប្រធានវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ

ស្របពេលសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន បានអូសបន្លាយចូលដល់ខែទី៣ហើយនោះ ផលវិបាកចេញពីសង្គ្រាមនេះ នឹងបន្ថែមសម្ពាធកាន់តែអាក្រក់ថែមទៀតដល់សេដ្ឋកិច្ចពិភពលោក ដែលកំពុងរងគ្រោះពីវិបត្តិកូវីដ-១៩ ពិសេសលើច្រវាក់ផ្គត់ផ្គង់សកល។ យោងរបាយការណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) សង្គ្រាមនេះនឹងធ្វើឱ្យកំណើនពាណិជ្ជកម្មសកល ដែលត្រូវបាន គេរំពឹងថានឹងកើនដល់ ៤,៧% ធ្លាក់មកនៅត្រឹមកំណើន ២,៥% វិញនៅឆ្នាំ២០២២។ អង្គការសហប្រជាជាតិ ដែលជាស្ថាប័នអន្តររដ្ឋាភិបាលមានអាណត្តិក្នុងការការពារសន្តិភាព និងសន្តិសុខសកល បានព្យាយាមស្វែងរកដំណោះស្រាយយ៉ាងស្វិតស្វាញ ព្រមទាំងបានអំពាវនាវដល់គ្រប់ភាគីនៃជម្លោះ ឱ្យយកមនុស្សធម៌ ជាអាទិភាពបំផុត។ សេចក្តីសម្រេចចិត្តលេខ A/ES-11/L.1 ដែលត្រូវបានអនុម័តដោយមហាសន្និបាទអង្គការសហប្រជាជាតិ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២ ជាមួយនឹងសម្លេងគាំទ្រ ១៤១ សម្លេង គឺជាកិច្ចខិតខំប្រឹងប្រែងមួយ ទោះបីខ្លឹមសារនៃសេចក្តីសម្រេចចិត្តនេះ មានអនុភាពត្រឹមថ្កោលទោសសកម្មភាពរបស់ប្រទេសរុស្ស៊ីនៅក្នុងអ៊ុយក្រែនក្តី។ លើសពីនេះ សេចក្តីសម្រេចមួយទៀតរបស់ស្ថាប័នដដែលនេះដែលត្រូវបានអនុម័តកាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ ក្នុងការព្យួរសមាជិកភាពរបស់ប្រទេសរុស្ស៊ីពីក្រុមប្រឹក្សាសិទ្ធិមនុស្ស ក៏ត្រូវបានគេឃើញថា ជាកិច្ចប្រឹងប្រែងមួយទៀត ទោះបីជាប្រសិទ្ធភាពនៃសេចក្តីសម្រេចចិត្តនេះអាស្រ័យលើឆន្ទៈរបស់រុស្ស៊ីក្នុងសកម្មភាពរបស់ខ្លួននៅប្រទេសអ៊ុយក្រែនក៏ដោយ។ អ្វីដែលមិនអាចប្រកែកបាននោះគឺថា ទោះបីជាសេចក្តីសម្រេចចិត្តទាំងនេះ ត្រូវបានអនុម័តជាធរមានក្តី ក៏សេចក្តីសម្រេចចិត្តទាំងនេះមិនមានអនុភាពគតិយុត្តគ្រប់គ្រាន់ក្នុងការបង្ខំឱ្យប្រទេសណាមួយទទួលអនុវត្តឱ្យខានតែបានឡើយ។ ស្របពេលដែលអង្គការសហប្រជាជាតិត្រូវបានគេឃើញថា មិនមានលទ្ធភាពបង្ខំឱ្យប្រទេសរុស្ស៊ីទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួននៅប្រទេសអ៊ុយក្រែន ការអំពាវនាវដោយប្រទេសនានាក្នុងការឱ្យមានយុទ្ធនាការដាក់ទណ្ឌកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើប្រទេសរុស្ស៊ីបានក្លាយជាឧបាស្រ័យមួយ ទោះជាមិនមានធម្មានុរូបគ្រប់គ្រាន់ក៏ដោយ។ ព័ត៌មានស្តីអំពីមហាសេដ្ឋី និងធុរកិច្ចរុស្ស៊ីដែលត្រូវបានរងទណ្ឌកម្មទាំងនេះ បានក្លាយជាប្រធានបទក្តៅគគុកលើពិភពលោក។ ទន្ទឹមនឹងការពិភាក្សាដេញដោលពីគ្រប់មជ្ឈដ្ឋាន សង្គ្រាមរុស្ស៊ី-អ៊ុយក្រែននេះបានទាញអង្គការ WTO ចូលមកក្នុងដំណើរស្វែងរកដំណោះស្រាយនេះដែរ ហើយសំណួរក៏ចាប់ផ្តើមផុសផុលឡើង ថាតើអង្គការដែលមានអាណត្តិគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិនេះ មានវិធីបែបណាទៅក្នុងការជួយរំលត់ភ្លើងសង្គ្រាមក្នុងសហសម័យថ្មីនេះ។

កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២ តំណាងអចិន្ត្រៃយ៍របស់ប្រទេសអ៊ុយក្រែនប្រចាំទីក្រុងហ្សឺណែវ បានដាក់កំណត់ប្រាស្រ័យទាក់ទងផ្លូវការមួយ ទៅកាន់អង្គការ WTO ដោយអំពាវនាវឱ្យសមាជិករបស់អង្គការនេះ ចាត់វិធានការពាណិជ្ជកម្មជាបន្ទាន់ប្រឆាំងនឹងប្រទេសរុស្ស៊ី។ ការផ្អាកសកម្មភាពចរចារបស់រុស្ស៊ី និងពិចារណាបណ្តេញរុស្ស៊ីចេញពីអង្គការនេះ គឺស្ថិតក្នុងចំណោមការអំពាវនាវទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលអគ្គនាយិការរបស់អង្គការនេះ បានបញ្ជាក់ម្តងហើយម្តងទៀតថា ការបណ្តេញរុស្ស៊ីចេញពីអង្គការនេះ គឺមិនអាចអនុវត្តបានដោយស្របច្បាប់បានឡើយ ព្រោះមិនមានបទប្បញ្ញត្តិច្បាស់លាស់ណាមួយបានចែងពីវិធានការនេះទេ។ ការពិភាក្សាជាច្រើនបានលើកពីសេណារីយ៉ូក្នុងការធ្វើបែបនេះ នៅក្រោមមាត្រា X (កថាខណ្ឌទី៣) នៃកិច្ចព្រមព្រៀងម៉ារ៉ាកេស ឆ្នាំ១៩៩៥

ដែលសមាជិកអង្គការ WTO អាចបោះឆ្នោតលើសំណើកែប្រែសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកណាមួយ ដែលបន្ទាប់មកត្រូវការសម្លេងភាគច្រើន២/៣ ពីសមាជិកទាំងនោះ ហើយទាមទារការទទួលយកសំណើនេះពីសមាជិកដែលជាកម្មវត្ថុនៃសំណើនេះផងដែរ។ ក្នុងករណីសមាជិកដែលជាកម្មវត្ថុនៃសំណើនេះ មិនផ្តល់ការយល់ព្រមក្នុងការទទួលយកសំណើនេះទេ សំណើនេះអាចនឹងត្រូវឆ្លងកាត់ការបោះឆ្នោតម្តងទៀត ក្នុងសម្លេងភាគច្រើន ៣/៤ ហើយប្រសិនបើជោគជ័យ សមាជិកដែលជាកម្មវត្ថុនៃសំណើនេះ អាចដកខ្លួនចេញពីអង្គការនេះដោយខ្លួនឯង ឬបន្តនៅក្នុងអង្គការនេះក្រោមការព្រមព្រៀងពីសន្និសីទថ្នាក់រដ្ឋមន្ត្រី។ ទោះជាយ៉ាងណា ការធានាបាននូវសម្លេងភាគច្រើន ៣/៤ នៅអង្គការ WTO ប្រឆាំងនឹងរុស្ស៊ីដែលជាប្រទេសផ្គត់ផ្គង់ឧស្ម័ន និងថាមពលដ៏សំខាន់លើពិភពលោក គឺជាសុបិន្តពេលថ្ងៃមួយដែលពិបាកនឹងកើតឡើងណាស់។ ពិតណាស់ មានបទប្បញ្ញត្តិមួយ និយាយឱ្យចំគឺមាត្រា XV នៃកិច្ចព្រមព្រៀងម៉ារ៉ាកេស ឆ្នាំ១៩៩៥ ដែលផ្តល់សិទ្ធិដល់សមាជិកណាមួយក្នុងការដកខ្លួនចេញពីអង្គការ WTO តាមឆន្ទៈរបស់ខ្លួន ដោយឆ្លងកាត់នីតិវិធីផ្ទៃក្នុងមួយចំនួន (ដូចដែលធ្លាប់ប្រើដោយអតីតប្រធានាធិបតីអាមេរិក លោកដូណាល់ត្រាំ ក្នុងឆ្នាំ២០២២ កន្លងទៅ)។ ទោះជាយ៉ាងណា ការស្រម៉ៃពីការដកខ្លួនរបស់រុស្ស៊ីចេញពីអង្គការ WTO នៅក្រោមមាត្រានេះ គឺរឹតតែមិនអាចទៅរួច ដោយសារប្រទេសនេះបានខិតខំប្រឹងប្រែងចរចាជិតពីរទសវត្សរ៍មកហើយ ដើម្បីទទួលបានសមាជិកភាពនៅក្នុងអង្គការ WTO នៅឆ្នាំ២០១២។ ដូច្នេះ ***តើមានវិធានការផ្សេងទៀតដែលអង្គការ WTO អាចប្រើដែរឬទេ?***

ការដេញដេញដោលបានបន្តទៅដល់វិធានការរឹតត្បិតពាណិជ្ជកម្ម ដែលស្ថិតក្រោមបទប្បញ្ញត្តិលើកលែងមួយចំនួន នៃកិច្ចព្រមព្រៀងពាក់ព័ន្ធក្រោមអង្គការ WTO។ អ្នកច្បាប់ពាណិជ្ជកម្មជាច្រើន បានចង្អុលបង្ហាញពីមាត្រា XXI នៃ កិច្ចព្រមព្រៀង GATT ១៩៩៤ ដែលធ្លុះបញ្ចាំងពីករណីមួយ ដែលប្រទេសរុស្ស៊ីបានប្រើប្រាស់មាត្រានេះ ប្រឆាំងនឹងអ៊ុយក្រែន កាលពីឆ្នាំ ២០១៤-២០១៦ (ជម្លោះលេខ WTO/DS-៥១២)។ មាត្រា XXI ស្តីពីការលើកលែងផ្នែកសន្តិសុខ [កថាខណ្ឌ (b)(iii)] អនុញ្ញាតឱ្យសមាជិកណាមួយ អាចអនុវត្តវិធានការរឹតត្បិតពាណិជ្ជកម្មដែល ***"ខ្លួនចាត់ទុកថាចាំបាច់សម្រាប់ការការពារផលប្រយោជន៍សន្តិសុខសំខាន់ៗរបស់ខ្លួន...ក្នុងគ្រាមានសង្គ្រាម ឬភាពអាសន្នផ្សេងទៀតនៅក្នុងទំនាក់ទំនងអន្តរជាតិ"*** ។ ក្នុងអំឡុងពេលនៃការហាមឃាត់ និងការរឹតត្បឹតរបស់រុស្ស៊ីលើការដឹកជញ្ជូនទំនិញរបស់អ៊ុយក្រែនតាមច្រកប្រទេសរុស្ស៊ី ដែលអ៊ុយក្រែនបានចោទប្រកាន់ថា ជាការរំលោភបំពានលើមាត្រា V និង X របស់កិច្ចព្រមព្រៀង GATT និងពិធីសារសិទ្ធិចំណុះរបស់រុស្ស៊ី (កថាខណ្ឌ៧.២) ប្រទេសរុស្ស៊ីបានព្យាយាមបង្ហាញថា វិធានការរបស់ខ្លួនគឺស្របនឹងមាត្រា XXI នៃកិច្ចព្រមព្រៀង GATT ហើយក្រុមជំនុំជម្រះរបស់អង្គការ WTO ក៏បានឯកភាពលើការបកស្រាយរបស់ប្រទេសរុស្ស៊ីផងដែរ។ ការឈ្លានពានរបស់រុស្ស៊ីលើអ៊ុយក្រែននៅឆ្នាំ២០២២ គឺជាការឆ្លុះបញ្ចាំងដ៏ជាក់លាក់មួយលើករណីយុត្តិសាស្ត្រលើកឡើងខាងនេះ ហើយអ៊ុយក្រែនបានលើកហេតុផលដូចគ្នាថា វិធានការរឹតត្បិតពាណិជ្ជកម្ម ក្នុងវិធីនៃការហាមឃាត់ ឬការរឹតត្បិតការនាំចូល-នាំចេញពី/ទៅប្រទេសរុស្ស៊ី គឺត្រូវបានអនុញ្ញាតនៅក្រោមមាត្រា XXI នៃកិច្ចព្រមព្រៀង GATT នេះដែរ។ ទោះយ៉ាងណា មានការងារជាច្រើនដែលសេសសល់ពាក់ព័ន្ធនឹងការបកស្រាយខ្លឹមសារសំខាន់ៗនៃមាត្រាខាងលើ។ ឃ្លា *"ដែលខ្លួនចាត់ទុកថាចាំបាច់ដើម្បីការពារផលប្រយោជន៍សន្តិសុខសំខាន់ៗរបស់ខ្លួន"* ត្រូវបានទុកឱ្យសមាជិកដាក់វិធានការបែបនេះ បកស្រាយដោយខ្លួនឯង ដែលពឹងផ្អែកយ៉ាងស្មុគស្មាញលើភស្តុតាង និងកាលៈទេសៈជាក់ស្តែង។ ជាងនេះទៅទៀត ពាក្យ *'សង្គ្រាម'* ជាពាក្យនៃកម្មវត្ថុដែលមានលក្ខណៈរសើប ដែលរហូតមកដល់ពេលនេះ រុស្ស៊ីបានបកស្រាយម្តងហើយម្តងទៀតថា សកម្មភាពរបស់

ខ្លួនក្នុងប្រទេសអ៊ុយក្រែន ជា *"ប្រតិបត្តិការយោធាពិសេស"* មិនមែនសង្គ្រាមឡើយ។ ការកំណត់អត្ថន័យនៃ '*សង្គ្រាម*' ត្រូវបានទុកថា ជាកិច្ចការរបស់អង្គការសហប្រជាជាតិ រួមមានសេចក្តីសម្រេចចិត្តរបស់ UNGA និង UNSC ឬសាលក្រមរបស់ ICJ ជាដើម។

បកមកក្រោយវិញ មានការពិភាក្សានៅឆ្នាំ ១៩៨២ លើមាត្រា XXI នៃកិច្ចព្រមព្រៀង GATT ១៩៤៧ ហើយប្រទេសចូលរួម រួមមានសហរដ្ឋអាម៉េរិក កាណាដា អូស្ត្រាលី និងសហគមន៍សេដ្ឋកិច្ចអឺរ៉ុប (ឥឡូវហៅថា សហភាពអឺរ៉ុប) បានយល់ស្របថា សមាជិកដែលដាក់វិធានការរឹតត្បិតនេះគឺជាចៅក្រមតែមួយគត់ក្នុងការកំណត់នូវអ្វីដែលចាត់ទុកថាជា "ផលប្រយោជន៍សន្តិសុខ"ដែលត្រូវបានគំរាមកំហែង។ទោះបីជាបន្ទាប់ពីការសម្រេចចិត្តនៅឆ្នាំ១៩៨២ ក៏ដោយ នៅក្នុងជម្លោះពាណិជ្ជកម្មរវាងសហរដ្ឋអាម៉េរិកនិងនីការ៉ាហ្គា ក្នុងឆ្នាំ១៩៨៦ អង្គជំនុំជម្រះបានកត់សម្គាល់ថា បទប្បញ្ញត្តិនេះ (មាត្រា XXI) នឹងត្រូវបានបកស្រាយ ដោយផ្អែកលើគោលការណ៍នៃច្បាប់អន្តរជាតិ និងស្របតាមការសម្រេចចិត្តរបស់អង្គការសហប្រជាជាតិ ហើយថា អង្គជំនុំជម្រះមិនមានអាណត្តិក្នុងការពិនិត្យមើលសុពលភាពនៃការប្រើប្រាស់មាត្រានេះទេ។ នៅក្នុងកំណត់ប្រាស្រ័យទាក់ទងផ្លូវការរបស់រុស្ស៊ីទៅកាន់អង្គការ WTO កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ឆ្លើយតបទៅនឹងកំណត់ប្រាស្រ័យទាក់ទងផ្លូវការអ៊ុយក្រែន កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២ កន្លងទៅ ប្រទេសរុស្ស៊ីបានលើកឡើងនូវអំណះអំណាងជាច្រើន ដែលមួយក្នុងចំណោមនោះ គឺថា ចេតនារបស់សមាជិកមួយចំនួនក្នុងការបញ្ចូលបញ្ហាទឹកដីទៅក្នុងក្របខ័ណ្ឌអង្គការ WTO គឺជាហានិភ័យជាប្រព័ន្ធដល់អង្គការនេះដែលចាប់តាំងពីឆ្នាំ១៩៤៧ មកប្រទេស/ដែនដីសមាជិកបានព្យាយាមបញ្ចៀសនូវទំនាក់ទំនងរវាងបញ្ហាដែនដី និងពាណិជ្ជកម្ម បានដោយជោគជ័យ។

សរុបសេចក្តីមក ទោះបីជាអង្គការ WTO ត្រូវបានផ្តល់អាណត្តិចង្អៀតមួយក្នុងការជ្រើសរើសវិធានការពាណិជ្ជកម្មដើម្បីស្វែងរកសន្តិភាពក្នុងប្រទេសអ៊ុយក្រែនក៏ដោយ ក៏ការសម្រេចចិត្តក្នុងការកំណត់និងបកស្រាយខ្លឹមសារច្បាប់សំខាន់ៗមួយចំនួន ត្រូវបានអនុញ្ញាតឱ្យទៅភាគីជម្លោះប៉ុណ្ណោះ ដែលភាគីទាំងនោះអាចប្រើប្រាស់ភស្តុតាង និងកាលៈទេសៈជាក់ស្តែងក្នុងការតតាំងក្តីគ្នា។ ជាងនេះទៅទៀត អង្គការនេះតែងតែមានការប្រុងប្រយ័ត្នជាខ្លាំង ក្នុងការសម្រេចចិត្តរបស់ខ្លួន ព្រោះថាដំណោះស្រាយបែបណាមួយ នឹងក្លាយទៅជាយុត្តិសាស្ត្រសម្រាប់ករណីជម្លោះស្រដៀងគ្នានាពេលអនាគត ហើយអាចលើកទឹកចិត្តឱ្យសមាជិក ដែលមានជម្លោះដែនដីនឹងគ្នា ឱ្យមកតតាំងគ្នានៅអង្គការ WTO ដែរ ដែលជាទិដ្ឋភាពមួយត្រូវបានគេមើលឃើញថា នឹងធ្វើឱ្យប៉ះពាល់ដល់បេសកកម្មរបស់អង្គការនេះ ដែលពីដើមឡើយគ្រប់គ្រងតែកិច្ចការពាណិជ្ជកម្មប៉ុណ្ណោះ។ ជាការគួរឱ្យកត់សម្គាល់ផងដែរថា ការចរចារបស់ប្រទេសបេឡារុសក្នុងការចូលជាសមាជិករបស់អង្គការ WTO ក៏ត្រូវបានផ្អាកផងដែរ ក្រោយពីសេចក្តីថ្លែងការណ៍រួមមួយរបស់អង្គការនេះ កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ ដែលផ្តួចផ្តើមដោយក្រុមប្រទេស G20។ ប្រទេសបេឡារុស ត្រូវបានគេចោទប្រកាន់នៅអង្គការសហប្រជាជាតិកន្លងទៅថា បានគាំទ្រសកម្មភាពរបស់ប្រទេសរុស្ស៊ីនៅក្នុងប្រទេសអ៊ុយក្រែន។ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ សហភាពអឺរ៉ុប ក្រុមប្រទេស G20 និងប្រទេសដែលជាសម្ព័ន្ធមិត្តផ្សេងទៀត បានប្រកាសដកឋានៈ MFN របស់ប្រទេសរុស្ស៊ី និងបេឡារុស ចេញពីអង្គការ WTO ផងដែរ។

## HOW WILL WTO FIND ROOM FOR SOLUTIONS TO RUSSIA-UKRAINE WAR?

**Mr. Iengchhay HOR**
**Director of Trade Training and Research Institute**

As Russia-Ukraine war has wandered in its third month, consequences have exacerbated the already-hit global economy, particularly on global supply chain. According to World Trade Organization (WTO), the war would slow global trade growth from the projected 4.7% to only 2.5% in 2022.[1] The United Nations, an IGO mandated to safeguard global peace and security, has tried some stern resolves and called on all parties to put humanity on table. The Resolution No. A/ES-11/L.1 adopted on 02 March 2022 with 141 affirmative votes was an attempt despite only being to condemn Russia's actions in Ukraine. Moreover, the UN's Resolution adopted on 07 April 2022 which suspended Russia from the 47-member Human Rights Council [2] was another deliberation though the effect is conditional to Russia's will. Undeniably, even if adopted, such resolutions cited above render less enforcement power at the absence of coercive mechanisms against the wrong-doing members. As the UN alone is technically less prevailing to put Russia accountable, the calls on individual members to sanction Russia economically and financially have been another justification-questioned remedy. News of Russian tycoons and businesses facing sanctions has thus flooded the headlines. As debates intensify, the crisis by surprise got WTO on board and questions arose as to how this trade-inspired IGO can put down the flame of this high-time war.

On 02 March 2022, the Ukrainian permanent representative to Geneva submitted an official communication to WTO calling on the Members to take immediate trade actions against Russia; suspending Russia's negotiation activities and considering expelling Russia out of the group are among the calls. However, as the WTO DG has reiterated, expelling Russia from this IGO is legally impracticable as there are no explicit provisions enabling as such. Discussions therefor arose on the scenario enabled under Article X (para 3) of the Marrakesh Agreement 1995 through which WTO Members might vote on a proposal of altering a Member's rights and obligations which thereafter needs a 2/3 majority vote from the Members and at the acceptance of such proposal by the Member under consideration. In case such a subject Member provides no consent of acceptance, the proposal might undergo another 3/4 majority vote and, if succeeded, hand rights to that subject Member to either withdraw itself from this IGO or to remain at the Ministerial Conference's consensus. Notwithstanding, securing an affirmative 3/4 majority vote at WTO against Russia, the main global gas and energy supplier, is an impossible daydream. Indeed, there is a provision, Article XV of the Marrakesh Agreement 1995 to be exact, that gives rights to any Member to withdraw from WTO at its own will following some internal procedures (as once used by former US president Donald Trump in 2020). However, imagining Russia's self-withdrawal from WTO under such Article is far more remote from possibility given the country's decades-long negotiation efforts to acquire its WTO membership in 2012. Thus, are there any other measures WTO might resort to?

Debates go on to trade restrictive measures sheltered under some exception Articles of WTO Agreements. Lots of trade lawyers then point out to Article XXI of GATT 1994, at a careful reflection on Russia's invocation of such Article against Ukraine in 2014-2016 (WTO/DS-512). Article XXI on Security Exceptions [para (b)(iii) to be exact] allows any Member to apply trade restrictive measures which *'it considers necessary for the protection of its essential security interests…in time of war or other emergency in international relations'*. During Russia's bans and restrictions of Ukraine's transit of goods via Russia which Ukraine alleged as violations on GATT's Articles V and X and Russia's Accession Protocol (para. 7.2), Russia tried to justify that its measures were consistent

[1] Jonathan Josephs, 'Ukraine War to Halve Global Trade Growth, Warns WTO' (*BBC News*, 01 April 2022) <https://www.bbc.com/news/business-60949053> accessed 05 May 2022.

[2] *See* United Nations, 'UN General Assembly votes to suspend Russia from the Human Rights Council' (*United Nations,* 07 April 2022) <https://news.un.org/en/story/2022/04/1115782> accessed 02 May 2022.

with Article XXI of GATT and earned justification from the Panel of WTO DSB thereafter. The Russia's invasion of Ukraine in 2022 has been an ideal reflection on this case of jurisprudence and Ukraine has reasoned the same that trade restrictive measures, in ways of banning or restriction of import-export from/to Russia, are permissible under such Article XXI of GATT. However, there is lots of unfinished work on the interpretation of key substance of the Article per se. The phrase *'which it considers necessary to protect its essential security interests'* has been left to the Member imposing such measures itself, that it complexly lies in convincing evidence and the circumstances at issue. Moreover, the term 'war' is substantively subjective in interpretation that Russia has thus far only addressed its actions in Ukraine as a *'special military operation'*. The determination of 'war' is left to the works of the UN, including the resolutions of UNGA and UNSC or the ICJ's verdicts.

Back then, there were discussions in 1982 on Article XXI of GATT 1947, and the discussants, including the US, Canada, Australia, and the EEC (now EU), agreed that the Member imposing restrictive measures was the only judge to determine what 'essential security interest' threatened was. Despite following a decision in 1982[3], in a trade dispute between the US and Nicaragua in 1986, the Panel noted that this provision (Article XXI) shall be interpreted on the merit of international law principles and in harmony with the UN's decisions and that the Panel was precluded from examining the validity of this Article invocation.[4] In an official communication of Russia to WTO on 16 March 2022, in response to the Ukraine's one on 02 March 2022, Russia raised lots of arguments, one of which was that the intentions by some Members to include the issue of territoriality into the WTO framework were a systematic risk to this IGO which since 1947, as Russia argued, has been successfully avoiding any links of that issue with trade.[5]

In conclusion, though WTO is given a narrow room to opt for trade-related measures in pursuit of peace in Ukraine, the discretions to determine some key legal terms are left to the contesting Parties which leverage on the proof and circumstances at hand. Moreover, this IGO is always mindful of its decisions as any such resolves would therefor become a jurisprudence for similar succeeding cases and incite Members having territorial disputes to also advance their fights via WTO, a move seen to jeopardize the original trade inspirations of this IGO. It is also noted that Belarus's accession negotiations for WTO's membership have also been suspended following the WTO's Joint Statement on 24 March 2022 initiated by the G20 countries. Belarus has been alleged at UN of supporting Russia's actions in Ukraine.[6] On 15 March 2022, both Russia and Belarus also got their WTO's MFN-status stripped off by EU, the G20, and other like-minded nations.[7]

---

[3] *See* Interpretative Note of Article XXI of GATT, Security Exceptions (1982) 606: The CONTRACTING PARTIES decide that: (1) subject to the exception in Article XXI:a, contracting parties should be informed to the fullest extent possible of trade measures taken under Article XXI; (2) when action is taken under Article XXI, all contracting parties affected by such action retain their full rights under the General Agreement; and (3) the Council may be requested to give further consideration to this matter in due course".

[4] Panel Report, *United States—Trade Measures Affecting Nicaragua*, para. 5.2.

[5] WTO, 'Communication from the Russian Federation' (16 March 2022) [WT/GC/245].

[6] The Guardian, 'Belarus Slammed at UN for Abuses, Invasion Role' (*The Guardian,* 17 March 2022) <https://guardian. ng/news/belarus-slammed-at-un-for-abuses-invasion-role/> accessed 04 May 2022.

[7] *See* 'Statement by Executive Vice-President Dombrovskis on EU Decision to Stop Treating Russia as a Most-Favoured-Nation at the WTO' on 15 March 2022.

# About the iTrade Bulletin

iTrade Bulletin is an e-publication by the Trade Training and Research Institute of the Ministry of Commerce. This monthly bulletin provides brief updates on specific issues in Cambodia, the regions and the world. This knowledge-sharing through scientific researches in the multifaceted areas aims to highlight current trade news & statistics relevant to all social stakeholders.


**Honorable President**
H.E. Mr. PAN Sorasak

**Editorial Board**
- H.E. Mrs. CHAM Nimul (Chairwoman)
- H.E. Ms. SEREI Borapich
- Mr. HOR Iengchhay
- Mr. SOK Bunthorn

**Advisors**
- H.E. Mr. SIM Sokheng
- H.E. Mr. PENN Sovicheat
- H.E. Dr. TAT Puthsodary
- H.E. Prof. Shandre Mugan THANGAVELU

**People behind iTrade Bulletin**
- Mr. PAO Phireak
- Mr. CHINKET Tola
- Ms. YANGNY Chakriya
- Ms. CHEA Kunlak
- Ms. PHAL Yita
- Mr. LY Rithy
- Mr. SE Sokunvathna
- Mr. NY Atykunn


## Announcement

Academicians, researchers, students and public are welcome to contribute their academic works, on all disciplines and topics of relevant interest to trade, to the next publication of the iTrade Bulletin.

### Topics Covered:

- Domestic and International Trade
- Domestic and International Economics
- 4th Industrial Revolution (4IR) and Technology
- Social Issue
- Gender Equality
- Other relevant topics.

### Categories:

- Research articles
- Case reports
- Policy Briefs
- Commentaries or editorial

For more information, please scan


វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ - TTRI
https://ttri.info/
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA